# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៧...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០១

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ **ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា** ហៅកាត់ថា **កាមិនកូ** ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**កាមិនកូ** មានទីស្នាក់ការនៅរាជធានីភ្នំពេញ អគារលេខ ២៨ កាច់ជ្រុងផ្លូវលេខ ១៣ និងលេខ ១០៦ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កាមិនកូ** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាពផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**កាមិនកូ** ត្រូវស្ថិតក្រោមឥទ្ធិពលបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២ .-**

**កាមិនកូ មានគោលដៅ និងភារកិច្ច ដូចខាងក្រោម :**

១- **កាមិនកូ** ធ្វើអាជីវកម្មធានារ៉ាប់រង សហធានារ៉ាប់រង និងធានារ៉ាប់រងបន្ត លើគ្រប់ប្រភេទហានិភ័យ រួមទាំងធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងលើអាយុជីវិត ។

២- អនុវត្តគ្រប់កិច្ចការដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងអាជីវកម្មធានារ៉ាប់រង សហធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ។

៣- ចូលរួមតាមគ្រប់មធ្យោបាយជាមួយសហគ្រាស ឬក្រុមហ៊ុននានាដែលកំពុងដំណើរការ ឬជាមួយក្រុមហ៊ុនដែលនឹងដំណើរការនាពេលខាងមុខ ដូចជា ចូលហ៊ុន ចុះកិច្ចសន្យាពាណិជ្ជកម្ម ទិញភាគហ៊ុន និងចូលរួមរាល់កិច្ចការ ឬសហគ្រាសទាំងឡាយដែលផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍របស់ក្រុមហ៊ុន។

៤- ចូលរួមរាល់ប្រតិបត្តិការឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ចលនទ្រព្យ ឬ អចលនទ្រព្យផ្សារភ្ជាប់ដោយចំពោះ ឬមិនចំពោះ ទៅនឹងគោលបំណងរបស់ក្រុមហ៊ុន ឬអាចសម្រួលដល់សមិទ្ធផល និងការរីកចំរើននៃប្រតិបត្តិការខាងលើ ។

៥- ទទួលខុសត្រូវនិងចាត់ចែង ក្នុងការងារការពារសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់លើការងាររបស់ខ្លួន។

៦- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចគ្នានឹងអាជីវករ ។

៧- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពអោយមានប្រសិទ្ធភាព និងមានការរីកចំរើន ។

៨- **កាមិនកូ** ទទួលពីរដ្ឋនូវសិទ្ធិនិងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន។

**មាត្រា ៣ .-**

**កាមិនកូ** ត្រូវគោរពរបបពន្ធ និងអាករ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤ .-**

ដើមទុនដំបូងរបស់ **កាមិនកូ** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលទទួលបាននូវការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **កាមិនកូ** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលរដ្ឋបានប្រគល់ឱ្យ ហើយដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៥ .-**

បុគ្គលិករបស់ **កាមិនកូ** ត្រូវជ្រើសរើសពីចំណោមមន្ត្រីរាជការ នៃមុខងារសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាចជ្រើសរើសបុគ្គលិកខាងក្រៅបើយល់ឃើញថាចាំបាច់ ។ បុគ្គលិករបស់ **កាមិនកូ** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក អនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា ៦ .-**

**កាមិនកូ** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប ជាប្រធាន |
| -តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១រូប ជាសមាជិក |
| -តំណាងក្រសួងយុត្តិធម៌ | ១រូប ជាសមាជិក |
| -អគ្គនាយក **កាមិនកូ** | ជាសមាជិក |
| -តំណាងនិយោជិតរបស់ **កាមិនកូ** | ១រូប ជាសមាជិក |

**មាត្រា ៧ .-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៏ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច ឬនីតិសាស្ត្រ ឬពាណិជ្ជសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់ និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **កាមិនកូ** ។

**មាត្រា ៨ .-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាម **កាមិនកូ** ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :**

១- ផ្តល់ការយល់ព្រមលើគំរោងផែនការសហគ្រាស ដូចមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យនេះ

២- វាយតម្លៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសំរួលឱ្យបានសមស្របតាមសភាពការណ៏ ។

៣- ផ្តល់ការយល់ព្រម លើរបាយការណ៏ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៏ហិរញ្ញវត្ថុ និងរបាយការណ៏សេដ្ឋកិច្ច **កាមិនកូ** ។

៤- សម្រេចតាមសំណើរបស់អគ្គនាយក នូវវចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **កាមិនកូ** ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទ ដូចមានចែងក្នុងបទបញ្ជាជាធរមាន ។

៦- សម្រេចបង្កើត បើក ឬបិទភ្នាក់ងារ សាខា ឬការិយាល័យរបស់ **កាមិនកូ** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- ផ្តល់ការយល់ព្រមលើសំណើ នៃការបណ្តាក់ទុនសម្រាប់មូលនិធិទំនេររបស់ក្រុមហ៊ុន ។

៨- ផ្តល់ការយល់ព្រមលើសំណើទិញ ផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយមានវត្ថុបញ្ចាំ ឬដោយគ្មានវត្ថុបញ្ចាំ ឬការធានាផ្សេងៗទៀត លើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។

**មាត្រា ៩ .-**

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេលវេលា អាស្រ័យដោយអត្ថប្រយោជន៍របស់សហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក ដែលមានចំនួនបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ ដង ក្នុងរយៈពេល ៣ ខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានក្នុងអង្គប្រជុំ ចាត់ចែងបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃអង្គប្រជុំ ព្រមទាំងឯកសារ ដែលទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិចបីនាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយ ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្ដីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះណាតែមានការអនុម័ត ដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១០ .-**

សេចក្ដីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ និងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥ ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រជាប្រូវហែរ និងមានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើមត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលវត្តមាន និងលេខាធិការជ្រើសរើសដោយអគ្គនាយក ។

**មាត្រា ១១ .-**

អគ្គនាយកមានភារកិច្ចគ្រប់គ្រងការងារនៃ **ភាមិនភ្ន** ជាប្រក្រតី និងត្រូវបានតែងតាំងសម្រាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ តំណែងនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១២ .**

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ តំណាងឱ្យ **ភាមិភ្ន** និងទទួលខុសត្រូវចំពោះមុខតុលាការ ។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកមានភារកិច្ច :

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ សម្រេច និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមតំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ភាមិនភ្ន** ។

២- ទទួលបន្ទុកដឹកនាំ **ភាមិនភ្ន** ផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវាកម្ម និង ហិរញ្ញវត្ថុ ។

៣- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណាង ឬបញ្ឈប់ការងារ និងមានសិទ្ធិត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ភាមិនភ្ន** ដោយគោរពតាមលក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៥- តំណាងឱ្យ **ភាមិនភ្ន** និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់តវ៉ា ការពារក្តីឱ្យ **ភាមិនភ្ន** និងប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៣ .-**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៤ .-**

ការចុះនិងការអនុវត្តកិច្ចសន្យាដោយ **ភាមិនភ្ន** ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន ។

## ជំពូកទី៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៥ .-**

**ភាមិនភ្ន** កាន់កាប់គណនេយ្យរបស់ខ្លួន ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី ៣១ ខែមិនា នៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃ ព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ។

**មាត្រា ១៦ .-**

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្ដល់ការយល់ព្រមលើគម្រោងផែនការ ប្រចាំឆ្នាំរបស់ **គាមិនគូ** តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ .-**

ធនធាននៃ **គាមិនគូ** ជាអាទិ៍មាន :

-ប្រាក់ដើមទុនដែលរដ្ឋផ្ដល់ឱ្យ ( តុល្យការដំបូងនៅពេលបង្កើត)

-ប្រាក់ដើមទុនដែលរដ្ឋផ្ដល់ឱ្យបន្ថែម

-ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **គាមិនគូ**

-ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុ របស់ **គាមិនគូ**

-ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា ១៨ .-**

ចំណាយនៃ **គាមិនគូ** រួមមាន :

-ចំណាយប្រក្រតីសម្រាប់ដំណើរការ

-ចំណាយវិនិយោគ

-ចំណាយសងបំណុល

-ចំណាយផ្សេងៗ។

**មាត្រា ១៩ .-**

**គាមិនគូ** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់ តំរូវការរបស់ខ្លួន។

**មាត្រា ២០ .-**

**ភាមិនកូ** ត្រូវបង់ប្រាក់ចំណេញពិតប្រចាំឆ្នាំ ចូលថវិការដ្ឋចំនួន ៧០% ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះទាំងអស់ឱ្យសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍជាចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ **ភាមិនកូ** មានសិទ្ធិប្រើប្រាស់ឱ្យស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា ២១ .-**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២ .-**

រយៈពេល ១៥ ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ភាមិនកូ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ :

-កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

-គម្រោងផែនការរបស់ **ភាមិនកូ**

-របាយការណ៍ស្តីពីសកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **ភាមិនកូ** ។

**មាត្រា ២៣ .-**

ត្រូវបានដាក់ឱ្យនៅអម **ភាមិនកូ** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវបានតែងតាំង ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់ លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ២០ ដល់មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៥
-ឯកសារ-កាលប្បវត្តិ